# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២១

## ក្រុមហ៊ុនអូស្ត្រាលីចាប់ផ្តើមចម្រាញ់រ៉ែមាស នៅការដ្ឋានចម្រាញ់រ៉ែមាសដំបូង នៅកម្ពុជា។

ថ្ងៃនេះ លោក Luke Arnold ភារធារីស្ថានទូតអូស្ត្រាលី និង លោក Rhys Haynes លេខាធិការទី២ បានចូលរួមជាមួយ ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជាជាច្រើនរូបទៀត ក្នុងការចាប់ផ្តើមសកម្មភាពរុករករ៉ែមាស នៅគម្រោងរ៉ែមាសអូរខ្វាវ ក្នុងខេត្តមណ្ឌលគីរី។

ក្រុមហ៊ុន រ៉ឺនេសង់ មីនើរ៉ល (ខេមបូឌា) លីមីតធីត Renaissance Minerals (Cambodia) Limited ដែលគ្រប់គ្រងដោយក្រុមហ៊ុន Emerald Resources ចុះបញ្ជីនៅ Australian Stock Exchange (ASX) ត្រូវបានបង្កើតឡើង និងដំណើរការគម្រោងនេះ។ នេះជារោងចក្រចម្រាញ់រ៉ែមាស ជាលក្ខណៈពាណិជ្ជកម្មដំបូងរបស់កម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាប៉ាន់ប្រមាណថា គម្រោងនេះនឹងបង្កើតចំណូលពន្ធ និងសួយសារ ប្រមាណជាង ៣០០ លានដុល្លារអាមេរិច ក្នុងរយៈពេល ៧ឆ្នាំ ដែលនឹងផ្តល់ថវិកាចាំបាច់សម្រាប់សេវាកម្មសាធារណៈ និងជួយកាត់បន្ថយនូវផលប៉ះពាល់ដល់សេដ្ឋកិច្ចដោយសារជំងឺកូវីដ-១៩ ។

លោក Luke Arnold ភារធារីស្ថានទូតអូស្ត្រាលី បានមានប្រសាសន៍ថា "ស្ថានទូតអូស្ត្រាលីមានសេចក្តីរីករាយ ដែលអាជីវកម្មរ៉ែអូស្ត្រាលី កំពុងជួយគាំទ្រដល់គោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើពិពិធកម្មប្រភពវិនិយោគបរទេសរបស់ខ្លួន។ ការវិនិយោគពីអូស្ត្រាលី ដូចជាគម្រោងនេះ នឹងជួយដល់ប្រទេសកម្ពុជា ក្នុងការកសាងសេដ្ឋកិច្ចដែលមានភាពធន់ ព្រមទាំងទស្សនវិស័យយុទ្ធសាស្ត្រប្រកបដោយតុល្យភាព នៅក្នុងតំបន់របស់យើង។"

ក្រុមហ៊ុន Emerald Resources បានប្តេជ្ញាចិត្តអនុវត្តនូវស្តង់ដារខ្ពស់ទាំងលើ បរិស្ថាន សង្គម និងអភិបាលកិច្ច នៅក្នុងគម្រោងនេះ ដោយអនុលោមតាមគោលការណ៍ណែនាំរបស់ OECD សម្រាប់សហ

គ្រោសពហុជាតិ និងច្បាប់ពាក់ព័ន្ធរបស់ប្រទេសកម្ពុជា។ ស្ថានទូតយល់ថា របាយការណ៍ស្ដីពីផលប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងនេះ ជារបាយការណ៍ដំបូងដែលត្រូវបានធ្វើសវនកម្ម សមស្របទៅនឹងបទដ្ឋានបរិស្ថាននិងសង្គមនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។

លោក Arnold បានមានប្រសាសន៍បន្ថែមថា "ការធ្វើសវនកម្មសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ កំណត់លក្ខខណ្ឌខ្ពស់សម្រាប់គម្រោងនានានៅពេលអនាគត ហើយនឹងជួយធានាថា ឧស្សាហកម្មរ៉ែនៅកម្ពុជាដែលកំពុងលេចធ្លោ អាចទាក់ទាញចំណាប់អារម្មណ៍ពី ក្រុមហ៊ុនរុករករ៉ែអន្តរជាតិដែលមានគុណភាពខ្ពស់ ហើយនឹងអាចផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជា និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម។"

អូស្ត្រាលីជាប្រទេសនាំមុខគេនៅក្នុងឧស្សាហកម្មរ៉ែជាសកល និងជាប្រទេសដែលគាំទ្រដ៏មុតមាំលើអភិបាលកិច្ចល្អក្នុងវិស័យរ៉ែ។ រដ្ឋាភិបាលអូស្ត្រាលី គាំទ្រកម្មវិធីរ៉ែដែលមានគណនេយ្យភាព របស់អង្គការតម្លាភាពអន្តរជាតិ (Transparency International) ដែលបាននិងកំពុងធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា និងសហគមន៍ ដើម្បីបង្កើតការពិគ្រោះយោបល់ក្នុងស្រុកប្រកបដោយអត្ថន័យ លើសំណើរសកម្មភាពរុករករ៉ែ និងការគ្រប់គ្រងប្រាក់ចំណូល។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au